សារមន្ទីរ និង មណ្ឌលវប្បធម៌ និង មគ្គុទ្ទេសក៍ទេសចរណ៍

# បទដ្ឋានសុវត្ថិភាព សម្រាប់ MA

បទដ្ឋានសុវត្ថិភាពជាក់លាក់នៃកូវីដ-១៩ តាមកន្លែងការងារគឺត្រូវបានធ្វើឡើងដើម្បីផ្តល់ជូនម្ចាស់ និងប្រតិបត្តិករនៃកន្លែងអាជីវកម្ម ហើយកម្មករ និងអ្នកចូលទស្សនានឹងទទួលបានការណែនាំដើម្បីជួយការពារប្រឆាំងនឹងការរីករាលដាលនៃកូវីដ-១៩ ខណៈពេលដែលសារមន្ទីរបើកឡើងវិញ ។ កន្លែងអាជីវកម្មដែលត្រូវបានលើកឡើងក្រោមពាក្យថា "សារមន្ទីរ" នៅខាងក្រោម រួមមាន សារមន្ទីរ អាងចិញ្ចឹមត្រីសម្រាប់តាំង និងកន្លែងប្រវត្តិសាស្ត្រខាងក្នុងនិងក្រៅអគារ និងមគ្គុទេសទេសចរណ៍ ។

## ភាពចាំបាច់ បទដ្ឋានសុវត្ថិភាព




គម្លាតសង្គម

សារមន្ទីរនីមួយៗត្រូវត្រួតពិនិត្យការចេញចូលរបស់ភ្ញៀវ និងការកំណត់កន្លែងកាន់កាប់សម្រាប់អគារនីមួយៗ ដែលបើកចំហជាសាធារណៈគ្រប់ពេលវេលាចំពោះ៖

- ៤0% នៃការអនុញ្ញាតឱ្យកាន់កាប់ជាអតិបរមានៃសារមន្ទីរដូចដែលបានកត់ត្រានៅក្នុងលិខិតអនុញ្ញាតកាន់កាប់របស់ខ្លួន លើកំណត់ត្រាជាមួយនាយកដ្ឋានទទួលបន្ទុកខាងអគារទីក្រុង ឬ អ្នកកាន់កំណត់ត្រាក្រុងផ្សេងទៀត
- អគារដែលគ្មានដែនកំណត់នៃការកាន់កាប់ដែលមានការអនុញ្ញាតត្រូវបានកត់ត្រាទុកដោយអនុញ្ញាតឱ្យមានមនុស្សត្រឹមតែ ៨ នាក់ (រួមទាំងបុគ្គលិក) ក្នុង ១000 ហ្វីតការ៉េ នៃទំហំអាចចូលបាននៅក្នុង ឬ ខាងក្រៅអគារ
- ក្នុងករណីខ្លះ៖ បើគ្មានទីធ្លាព័ទ្ធជុំវិញនៅក្នុងអាគារ ការកាន់កាប់មនុស្សមិនអាចលើសពី ៨ នាក់ក្នុង ១.000 ហ្វីតការ៉េ
- រាល់អ្នករាប់ទំនិញនិងការគិតលុយ គួររួមបញ្ចូលទាំងអតិថិជន បុគ្គលិក និងកម្មករផ្សេងទៀត

ធានាឱ្យបាននូវគម្លាតពីគ្នាពី ៦ ហ្វីត ឡើងទៅរវាងបុគ្គលម្នាក់ៗ តាមដែលអាចធ្វើទៅបាន៖

- បិទ ឬ កំណត់រចនាសម្ពន្ធកន្លែងធ្វើការរួមរបស់កម្មករ និងតំបន់ដែលមានដង់ស៊ីតេខ្ពស់ដែលជាកន្លែងកម្មករទំនងជាអាចប្រមូលផ្តុំគ្នាបាន (ឧទាហរណ៍..បន្ទប់សម្រាក កន្លែងបរិភោគអាហារ) អនុញ្ញាតឱ្យមានគម្លាតសង្គម
- របាំងបែងចែកត្រូវតែចែកឱ្យដាច់ពីគ្នារវាងកន្លែងធ្វើការនីមួយៗ (របាំងបែងចែកត្រូវមានកម្ពស់យ៉ាងតិច ៦ ហ្វីត)
- តំឡើងរបាំងការពាររូបវន្តសម្រាប់បញ្ជរនៃទីតាំងលក់សំបុត្រ កន្លែងត្រួតពិនិត្យចេញ ។ ល ។ បើអាចធ្វើទៅបាន
- ដំឡើងសញ្ញាសម្គាល់នៃគម្លាតសង្គម ដើម្បីលើកទឹកចិត្តអតិថិជនឱ្យនៅចម្ងាយ ៦ ហ្វីត ពីគ្នា (ឧទាហរណ៍...ខ្សែបន្ទាត់នៅក្រៅសារមន្ទីរ បើអាចមាន ខ្សែបន្ទាត់នៅកន្លែងបង់លុយ និងខ្សែបន្ទាត់ប្រើសម្រាប់បន្ទប់ទឹក)
- គូសសម្គាល់បន្ទប់តាំងពិព័រណ៍និងសាលដទៃទៀត ដើម្បីចង្អុលបង្ហាញពីការនៅដាច់ដោយឡែកចម្ងាយ ៦ ហ្វីត ពីគ្នា

ដាក់ស្លាកសញ្ញាដែលអាចមើលឃើញយ៉ាងច្បាស់ទាក់ទងនឹងការរក្សាគម្លាតសង្គម ៦ ហ្វីត និងមិនអនុញ្ញាតឱ្យចូលក្នុងបន្ទប់រហូតដល់ការរក្សាអាចចម្ងាយធ្វើទៅបាន ។

បង្កើតទិសដៅផ្លូវដើរសម្រាប់ចរាចរណ៍ថ្មើរជើង ដើម្បីគ្រប់គ្រងចរាចរណ៍របស់អតិថិជនថ្មើរជើង បើអាចធ្វើទៅបាន ដើម្បីកាត់បន្ថយការទំនាក់ទំនង (ឧទាហរណ៍ ច្រកចេញចូលតែមួយ និងផ្លូវចេញទៅបន្ទប់ / តាំងពិព័រណ៍ ផ្លូវថ្មើរជើងតែមួយ) ។ ដាក់ស្លាកសញ្ញាដែលអាចមើលឃើញយ៉ាងច្បាស់ដោយផ្សារភ្ជាប់ជាមួយវិធានការផ្សេងៗ

ការញាំអាហារនិងពេលសម្រាករបស់បុគ្គលិកត្រូវនៅដាច់ដោយឡែកពីគ្នា ហើយការសម្រាកត្រូវកំណត់ចំនួនមនុស្សអតិបរមានៅកន្លែងតែមួយ និងធានាឱ្យបានគម្លាតផ្នែករាងកាយយ៉ាងហោចណាស ៦ ហ្វីត

តម្រូវឱ្យមានការបិទបាំងមុខសម្រាប់កម្មករ និង អតិថិជនទាំងអស់ លើកលែងតែកន្លែងដែលគ្មានសុវត្ថិភាពដោយសារស្ថានភាពសុខភាព ឬ ពិការភាព

លើកទឹកចិត្តឱ្យប្រើឧបករណ៍ណែនាំអេឡិចត្រូនិចកំណែថ្មី (ដូចជា ខិត្តប័ណ្ណ និង សៀវភៅណែនាំវិចិត្រសាល) តាមដែលអាចធ្វើទៅបាន ។ រាល់សម្ភារមគ្គុទេសក៍រូបវន្ត (ដូចជាខិត្តប័ណ្ណជាក្រដាស សៀវភៅណែនាំវិចិត្រសាល និងមគ្គុទេសក៍ជាសំលេង) ត្រូវបានបោះបង់ចោល ឬ ត្រូវបានធ្វើអនាម័យរវាងការប្រើប្រាស់នីមួយៗ ។ រាល់ឧបករណ៍សម្រាប់បម្រើខ្លួនឯង ត្រូវបានដកចេញ ហើយផ្ទុយទៅវិញរាល់សម្ភារទាំងអស់ត្រូវប្រគល់ឱ្យអតិថិជនដោយបុគ្គលិកម្នាក់ៗ

### ការកំណត់ទំហំក្រុមសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍

ប្រតិបត្តិករទេសចរណ៍នីមួយៗដែលប្រើឡានក្រុង ឬ យានជំនិះផ្សេងទៀត (ដូចជា រទេះរុញ កប៉ាល់ទេសចរណ៍ ឬ ទូកុទា) ត្រូវកំណត់ការកាន់កាប់គ្រប់ពេលវេលារហូតដល់ ៥0% នៃទេសចរណ៍តាមយានយន្ត ឬ កប៉ាល់ដូចដែលមានចែងនៅក្នុងលិខិតអនុញ្ញាតកាន់កាប់ជាអតិបរមារបស់ខ្លួនលើកំណត់ត្រាជាមួយអ្នកកាន់កំណត់ត្រាក្រុងដែលពាក់ព័ន្ធ

ដែនកំណត់នៃការធ្វើដំណើរដោយប្រើកប៉ាល់ដែលមានទីធ្លាទំនេរសម្រាប់ផ្ទុកអ្នកដំណើរ ត្រូវកំណត់ដោយយោងតាមរូបមន្តដែលបានប្រើដើម្បីកំណត់ដែនកំណត់នៃការជួលទូក ដែលមានចែងក្នុងច្បាប់ស្តីពី សុវត្ថិភាពការងារ និង ការបើកឡើងវិញសម្រាប់ការជួលនាវាលក្ខណៈសាធារណៈ និង ដោយឯកជន

ដំណើរកម្សាន្តតាមកន្លែងនីមួយៗដែលគ្មានកំណត់ការកាន់កាប់មានកំណត់ត្រាជាក់លាក់ ត្រូវកំណត់ការកាន់កាប់ដោយផ្អែកលើគោលការណ៍ណែនាំពីព្រឹត្តិការណ៍ក្នុងនិងក្រៅអគារ នៅលើ វិបសាយថ៍នៃបើកដំណើរការឡើងវិញ

រាល់អ្នកគ្រប់គ្រងនិងគិតលុយ គួរត្រូវបានរួមបញ្ចូលទាំងអតិថិជន និងកម្មករ

ក្រុមអ្នកដំណើរគួរតែត្រូវបានបែងចែកចេញពីយានយន្តដោយកៅអីដែលទំនេរ ។ ប្រសិនបើមិនអាចធ្វើទៅបានទេ យានយន្តគួរតែត្រូវបើកបង្អួចចំហ

ប្រតិបត្តិករទេសចរណ៍ត្រូវកំណត់ទំហំក្រុមក្នុងដំណើរកម្សាន្តថ្មើរជើង ដែលមិនលើសពី ១0 នាក់

មគ្គុទេសក៍ និង ភ្ញៀវ គួរតែរក្សាចម្ងាយ ៦ ហ្វីត និងពាក់គម្របមុខ

### ការអនុវត្តដ៏ប្រសើរដែលត្រូវបានណែនាំ

អាជីវកម្មទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យផ្តល់ជូនម៉ោងពិសេស ឬ យកចិត្តទុកដាក់សម្រាប់អ្នកដែលមានហានិភ័យខ្ពស់ដូចដែលបានកំណត់ដោយ CDC

លើកទឹកចិត្តដល់ការលក់សំបុត្រតាមអ៊ីនធឺណិត និងវិធីបង់ប្រាក់ដោយគ្មានការទាក់ទង ប្រសិនបើអាច

ពិចារណាលើការប្រើសំបុត្រចូល / ការកក់ទុកជាមុន និងកំណត់ពេលវេលាសម្រាប់ការទស្សនា ហើយពេលវេលាដែលបានកំណត់សម្រាប់អ្នកទស្សនាត្រូវអនុលោមតាមដែនកំណត់នៃការកាន់កាប់

សូមផ្តល់មតិយោបល់ចំពោះការកំណត់ចំនួនភ្ញៀវទេសចរណ៍ដែលមកពីសមាជិកគ្រួសារតែមួយ

ព័ត៌មានលម្អិតបន្ថែមស្តីពីវិធានការដាក់លាក់អាចរកបាននៅ https://www.mass.gov/info-details/reopening-massachusetts

### សារមន្ទីរ និង មណ្ឌលវប្បធម៌ និង មគ្គុទ្ទេសក៍ទេសចរណ៍

# បទដ្ឋានសុវត្ថិភាព សម្រាប់ MA

## ភាពចាំបាច់ បទដ្ឋានសុវត្ថិភាព

### វិធានការ អនាម័យ

ធានាថាការចូលទៅកន្លែងលាងដៃត្រូវមានសាប៊ូ និងមានទឹកទុយូ និងអនុញ្ញាតឱ្យមានពេលវេលាសម្រាកគ្រប់គ្រាន់សម្រាប់កម្មករលាងដៃឱ្យបានញឹកញាប់ ។ ទឹកលាងដៃដែលមានជាតិអាល់កុលយ៉ាងតិច ៦០% អាចនឹងត្រូវបានប្រើជំនួស

ផ្គត់ផ្គង់ផលិតផលសម្អាតឱ្យបានគ្រប់គ្រាន់ទៅកម្មករនៅតាមទីតាំងផ្សេងៗនៃកន្លែងធ្វើការ ( ឧទាហរណ៍.. ក្រដាសអនាម័យ ក្រដាសជូតសម្លាប់មេរោគ )

ទឹកលាងដៃដែលមានជាតិអាល់កុលយ៉ាងតិច ៦០% គួរតែមាននៅតាមច្រកចេញចូល និងកន្លែងបរិភោគអាហារ សម្រាប់កម្មករ និង អតិថិជន

ជៀសវាងការចែកចាយ និងប្រើប្រាស់សម្ភាររួមរបស់កម្មករ

កម្ចាត់មេរោគលើឧបករណ៍ប្រើប្រាស់រួម មុនពេលប្រើប្រាស់ដោយកម្មករដទៃផ្សេងទៀត

ដាក់ស្លាកសញ្ញាដែលអាចមើលឃើញនៅនឹងកន្លែងធ្វើការដល់កម្មករ អំពីវិធានការសុវត្ថិភាព និងអនាម័យ

---

### ការរៀបចំបុគ្គលិកនិង ប្រតិបត្តិការ

ផ្តល់ការបណ្តុះបណ្តាលដល់កម្មករអំពីព័ត៌មានសុវត្ថិភាពនាពេលបច្ចុប្បន្ន និងការប្រុងប្រយ័ត្នរួមមានអនាម័យ និងវិធានការសុវត្ថិភាពផ្សេងៗទៀតក្នុងការកាត់បន្ថយនូវការចម្លងមេរោគដោយរាប់បញ្ចូលទាំង៖

- គម្លាតសង្គម ការលាងដៃ ការប្រើម៉ាស់គ្របមុខឱ្យបានត្រឹមត្រូវ
- ត្រូវត្រួតពិនិត្យដោយខ្លួនឯងនៅផ្ទះរួមទាំងការត្រួតពិនិត្យសីតុណ្ហភាពនិងរោគសញ្ញាផ្សេងៗ
- ប្រសិនបើឈឺ ចាំបាច់មិនត្រូវមកធ្វើការ
- ប្រសិនបើរោគសញ្ញាកាន់តែធ្ងន់ធ្ងរត្រូវស្វែងរកការព្យាបាល
- លក្ខខណ្ឌសុខភាពមូលដ្ឋានដែលអាចធ្វើឱ្យបុគ្គលងាយនឹងឆ្លង និងទទួលរងពីករណីធ្ងន់ធ្ងរនៃវីរុស

កែតម្រូវម៉ោងការងារ និងការផ្លាស់ប្តូរវេនការងារ (ប្រសិនបើមានការធ្វើការដោយផ្ទាល់ ក្រុមការងារគួរមានកាលវិភាគផ្សេងៗគ្នា ឬការមកដល់ / ចាកចេញយឺត )ដើម្បីកាត់បន្ថយការទាក់ទងគ្នារវាងកម្មករនិងកាត់បន្ថយការកកស្ទះ

អាជីវកម្មទាំងអស់គួរតែកាត់បន្ថយម៉ោងប្រតិបត្តិការ ដើម្បីអនុញ្ញាតឱ្យមានម៉ោងធ្វើអនាម័យ និង សម្អាត

កំណត់ចំនួនភ្ញៀវនិងអ្នកលក់នៅនឹងកន្លែង ហើយការដឹកជញ្ជូននិងការចែកចាយគួរតែត្រូវបានបញ្ចប់នៅក្នុងតំបន់ដែលបានកំណត់

ក្រុមហ៊ុនទាំងអស់ត្រូវតែត្រួតពិនិត្យកម្មករតាមវេននីមួយៗដោយធានាដូចខាងក្រោះ

- កម្មក្ករមិនមានរោគសញ្ញាណាមួយដូចជាក្តៅខ្លួន ( ១០០.០ ឡើងទៅ ) ឬ ញាក់ ក្អក ដង្ហើមខ្លី ឈឺបំពង់ក ហត់នឿយ ឈឺក្បាល ឈឺសាច់ដុំ / ឈឺខ្លួន ហៀរសំបោរ / ហូរឈាមតាមច្រមុះ បាត់បង់រសជាតិ ឬ ក្លិនថ្មីៗ ឬ ចង្អោរ ក្អួត ឬ រាគ
- កម្មករមិនមាន "ទំនាក់ទំនងជិតស្និទ្ធ" ជាមួយបុគ្គលដែលត្រូវបានគេធ្វើរោគវិនិច្ឆ័យថាមានកូវីដ-១៩ “ ទំនាក់ទំនងជិតស្និទ្ធ” មានន័យថាការរស់នៅក្នុងគ្រួសារតែមួយជាមួយមនុស្សដែលបានធ្វើតេស្តវិជ្ជមានកូវីដ-១៩ ព្រមទាំងការយកចិត្តទុកដាក់ចំពោះអ្នកដែលបានធ្វើតេស្តវិជ្ជមានកូវីដ-១៩ ហើយត្រូវស្ថិតនៅក្នុងចម្ងាយ ៦ ហ្វីតនៃមនុស្សម្នាក់ដែលបានធ្វើតេស្តវិជ្ជមានកូវីដ-១៩ រយៈពេល ១៥ នាទីឬលើសពីនេះឬទាក់ទងដោយផ្ទាល់ ( ឧទាហរណ៍ ការប្រើឧបករណ៍ផ្ទះបាយរួមដែលត្រូវបានគេក្អកដាក់ ) ពីមនុស្សម្នាក់ដែលបានធ្វើតេស្តវិជ្ជមានកូវីដ-១៩ ខណៈពេលដែលមនុស្សនោះមានចេញរោគសញ្ញា ។
- កម្មករទាំងអស់ដែលមិនត្រូវបានស្នើសុំឱ្យផ្តាច់ខ្លួន ឬ ផ្តាច់ខ្លួនដោយវេជ្ជបណ្ឌិត ឬ មន្ត្រីសុខភាពសាធារណៈក្នុងមូលដ្ឋានឡើយ
- កម្មករដែលខកខានមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យខាងលើត្រូវតែបញ្ជូនទៅផ្ទះវិញ

រក្សាកំណត់ហេតុកម្មករនិងអតិថិជន ដើម្បីងាយស្រួលក្នុងការធ្វើទំនាក់ទំនង ( ឈ្មោះ កាលបរិច្ឆេទ ពេលវេលា ព័ត៌មានទំនាក់ទំនង )

កម្មករដែលចាប់ផ្តើមឈឺ មិនត្រូវមានវត្តមាននៅកន្លែងធ្វើការទេ

ប្រសិនបើនិយោជកត្រូវបានគេជូនដំណឹងអំពីករណីវិជ្ជមាននៅកន្លែងធ្វើការ និយោជកត្រូវជូនដំណឹងទៅក្រុមប្រឹក្សាសុខភាពមូលដ្ឋាន ( LBOH ) ក្នុងទីក្រុង ឬ ប្រជុំជនដែលស្ថិតនៅនឹងកន្លែងធ្វើការផ្ទាល់ និងធ្វើការជាមួយ LBOH តាមការស្នើ ដើម្បីណែនាំកម្មករឱ្យនៅឆ្ងាយពីគេ និងឃុំខ្លួនឯង ។ ការធ្វើតេស្តលើកម្មករផ្សេងទៀតអាចត្រូវបាន ផ្តល់ជាមតិយោបល់ដែលស្របទៅនឹងការណែនាំនិង / ឬតាមសំណើរបស់ LBOH

ជូនដំណឹងដល់កម្មករ និង អ្នកទស្សនានូវព័ត៌មានសុខភាពសំខាន់ៗ និងវិធានការពាក់ព័ន្ធនឹងសុវត្ថិភាពដែលមានចែងក្នុង បទដ្ឋានសុវត្ថិភាពចាំបាច់សម្រាប់កន្លែងការងារ របស់សហគមន៍

ការតាំងពិព័រណ៍អន្តរកម្ម ( ឧទាហរណ៍ ការប៉ះ និង មានអារម្មណ៍ចំពោះការតាំងពិព័រណ៍ កន្លែងលេង ) គួរតែត្រូវបានបិទ ឬ ត្រូវបានកំណត់រចនាសម្ព័ន្ធដោយមានចម្ងាយ ៦ ហ្វីត ពីចម្ងាយដែលត្រូវបានសម្គាល់យ៉ាងច្បាស់ ហើយទទួលបានការសម្អាត និង ការកម្ចាត់រោគជាញឹកញាប់ ។ កន្លែងធ្វើអនាម័យដៃ ( សាប៊ូ និង ទឹក ឬ ទឹកលាងដៃដែលមានជាតិអាល់កុល ) គួរតែមានដើម្បីលើកកម្ពស់ការប្រើប្រាស់ដោយសុវត្ថិភាព

ព័ត៌មានលម្អិតបន្ថែមស្តីពីវិធានការដាក់លាក់អាចរកបាននៅ https://www.mass.gov/info-details/reopening-massachusetts

# បទដ្ឋានសុវត្ថិភាព សម្រាប់ MA

## ភាពចាំបាច់ បទដ្ឋានសុវត្ថិភាព

### ការរៀបចំបុគ្គលិកនិងប្រតិបត្តិការ

កន្លែងផ្តល់សេវាកម្ម និងសេវាកម្មបន្ថែមនៅនឹងកន្លែងអាចបើកនិងដំណើរការនៅពេលដែលកន្លែងផ្តល់សេវាកម្មនិងសេវាកម្មបន្ថែមទាំងនោះត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការ ក្រោមផែនការបើកដំណើរការជាផ្លូវការរបស់រដ្ឋ ហើយបន្ទាប់មកត្រូវតែប្រកាន់ខ្ជាប់នូវវិធានការសុវត្ថិភាពជាក់លាក់ដែលមាននៅលើ [របាយការណ៍ផែនការបើកឡើងវិញ] ដែលអាចអនុវត្តបាន ចំពោះកន្លែងផ្តល់សេវាកម្មឬសេវាកម្ម ។ ឧទាហរណ៍ដោយរាប់បញ្ចូលទាំង៖

- ភោជនីយដ្ឋានទាំងអស់ ត្រូវអនុវត្តតាមការណែនាំចុងក្រោយស្តីពីភោជនីយដ្ឋាន
- ហាងលក់វត្ថុអនុស្សាវរីយ៍៖ ត្រូវអនុវត្តតាមការណែនាំចុងក្រោយស្តីពីការលក់រាយ
- ឆាកសម្តែង ត្រូវអនុវត្តតាមការណែនាំចុងក្រោយស្តីពីឆាកសម្តែង
- ព្រឹត្តិការណ៍ផ្សេងៗ៖ ត្រូវតែធ្វើតាមគោលការណ៍ណែនាំចុងក្រោយស្តីពីព្រឹត្តិការណ៍ក្នុង និង ក្រៅអគារ

**ការអនុវត្តដ៏ប្រសើរដែលត្រូវបានណែនាំ**

លើកទឹកចិត្តដល់កម្មករដែលងាយរងគ្រោះដោយកូវីដ-១៩ យោងតាមមជ្ឈមណ្ឌលត្រួតពិនិត្យជម្ងឺ ( ឧទាហរណ៍ ដោយសារអាយុ ឬ លក្ខខណ្ឌមូលដ្ឋាន ) ត្រូវស្នាក់នៅផ្ទះ

លើកទឹកចិត្តកម្មករដែលមានរោគសញ្ញា ឬ សង្ស័យមានទំនាក់ទំនងជិតស្និទ្ធនឹងអ្នកមានរោគសញ្ញាកូវីដ-១៩ ត្រូវរាយការណ៍ទៅនិយោជក

លើកទឹកចិត្តកម្មករដែលធ្វើតេស្តវិជ្ជមានសំរាប់កូវីដ-១៩ ដើម្បីរាយការណ៍ទៅការិយាល័យនិយោជកក្នុងគោលបំណងសម្អាត / កម្ចាត់មេរោគ និងតាមដានរាល់ទំនាក់ទំនង ។

### ការសម្អាត និង ការកម្ចាត់មេរោគ

សម្អាតផ្ទៃដែលប៉ះញឹកញាប់ជាធម្មតានៅក្នុងបន្ទប់ទឹក ( ឧទាហរណ៍ ចានបង្គន់ កៅអី ដៃទ្វារ គន្លឹះទ្វារ កន្លែងលាងដៃ ប្រអប់ដាក់ក្រដាសជូត ប្រអប់ដាក់សាប៊ូ ) ឱ្យបានញឹកញាប់ ដោយអនុលោមតាមគោលការណ៍ណែនាំរបស់ CDC

អនុវត្តការលាងសម្អាតញឹកញាប់និងការកម្ចាត់មេរោគនៅនឹងកន្លែង ( យ៉ាងហោចណាស់រៀងរាល់ថ្ងៃ និង ញឹកញាប់ ប្រសិនបើអាច )

រក្សាកំណត់ហេតុសម្អាតដែលរួមមានកាលបរិច្ឆេទ ពេលវេលា និងទំហំនៃការសម្អាត

ធ្វើការកម្ចាត់មេរោគឱ្យបានញឹកញាប់នូវតំបន់ដែលមានការចម្លងខ្ពស់ និង ផ្ទៃដែលប៉ះពាល់ញឹកញាប់ ( ឧទាហរណ៍...ដៃទ្វារ បន្ទប់ទឹក បញ្ចូលក់សំបុត្រ បន្ទប់សម្រាកបុគ្គលិក )

ក្នុងករណីមានករណីវិជ្ជមាន សូមបិទកន្លែងសម្រាប់ការសម្អាត និងកម្ចាត់មេរោគនៅកន្លែងធ្វើការ ស្របតាមការណែនាំរបស់ CDC នាពេលបច្ចុប្បន្ន

**ការអនុវត្តដ៏ប្រសើរដែលត្រូវបានណែនាំ**

បើកបង្អួច និងទ្វារ ដើម្បីបង្កើនលំហូរខ្យល់តាមដែលអាចធ្វើទៅបាន